# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**
លេខ ៤៥០.កយ.រប-២០០៦

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោកប្រធានតុលាការខេត្ត ក្រុង**

**កម្មវត្ថុ:** អំពីការប្រើប្រាស់ទម្រង់ ដីកាការពារ ដែលមានបញ្ញត្តិនៅក្នុងច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ ។

**យោង:** ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

-លិខិតលេខ ៦៣៣ កកន ចុះថ្ងៃទី២៣-១៥-២០០៥ របស់ក្រសួងកិច្ចការនារី ។

ខ្ញុំសូមជម្រាបអស់លោក-លោកស្រីថា ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចកាពារជនរងគ្រោះដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៦-០៩-២០០៥ ហើយបានចូលជាធរមានហើយនោះ មានបញ្ញត្តិមួយចំនួនបានចែងអំពីវិធានការ និងសមត្ថកិច្ចរបស់តុលាការខេត្ត-ក្រុង ក្នុងការដីកាការពារ ។

ដោយបច្ចុប្បន្ន យើងពុំទាន់មានទម្រង់សម្រាប់ឱ្យប្រើប្រាស់ដីកាការពារនេះ ជាផ្លូវការនៅឡើយអាស្រ័យហេតុនេះសូមលោក-លោកស្រី នៃតុលាការខេត្ត-ក្រុងទាំងអស់ប្រើប្រាស់នូវទម្រង់ដីកាការពារ ដែលមានបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់ អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនេះតាមទម្រង់ ដីកាសម្រេចកិច្ចការប្រញាប់ ដែលកំពុងប្រើប្រាស់ក្នុងពេលបច្ចុប្បន្ននេះជាបណ្តោះអាសន្នសិន ទម្រាំក្រសួងយុត្តិធម៌រៀបចំរួចរាល់នូវទម្រង់ដីកាការពារ សម្រាប់ឱ្យប្រើប្រាស់ជាផ្លូវការនាពេលខាងមុខនះ ។

ក្រសួងសង្ឃឹមថា អស់លោក-លោកស្រីប្រធានតុលាការខេត្ត-ក្រុង ទាំងអស់នឹងយកចិត្តទុកដាក់អនុវត្តតាមការណែនាំនេះឱ្យបានល្អប្រសើរ និងមានប្រសិទ្ធិភាពខ្ពស់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៦

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

ចម្លងជូន

-តុលាការ,មហាអយ្យការ,អយ្យការគ្រប់ជាន់ថ្នាក់
-ដើម្បីជ្រាប និងអនុវត្ត
-ក្រសួងកិច្ចការនារី
-ដើម្បីជ្រាប
-ឯកសារ-កាលប្បវត្តិ